**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ អ្នកជំនាញ អ.ស.ប ថ្កោលទោសការសម្រេចផ្តន្ទាទោសអ្នកការពារសិទ្ធិបរិស្ថាន ជំរុញឲ្យដោះលែងពួកគេ

ទីក្រុងហ្សឺណែវ (០៧ ឧសភា ២០២១) – នៅថ្ងៃនេះ អ្នកជំនាញមួយរូបរបស់ អ.ស.ប បានថ្កោលទោសការសម្រេចរបស់តុលាការកម្ពុជា ផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្សផ្នែកបរិស្ថានចំនួនបីរូប ដាក់ពន្ធនាគាររយៈពេលរហូតដល់ ២០ ខែ ហើយបានជំរុញឱ្យរដ្ឋាភិបាលដោះលែងពួកគេជាបន្ទាន់និងដោយគ្មានល័ក្ខខ័ណ្ឌ ។

អ្នកការពារសិទ្ធិមនុស្សដែលត្រូវតុលាការផ្តន្ទាទោសទាំងនោះ រួមមាន លោក ថុន រដ្ឋា កញ្ញា ឡុង គន្ធា និងកញ្ញា ភួន កែវរស្មី ដែលជាសមាជិកអង្គការមាតាធម្មជាតិ (អិម អិន ស៊ី) ជាអង្គការមិនមែនរដ្ឋាភិបាលខាងផ្នែកបរិស្ថានដែលតស៊ូមតិ ដើម្បីការពារ និងអភិរក្សបរិស្ថានធម្មជាតិកម្ពុជា និងគាំទ្រសហគមន៍មូលដ្ឋានក្នុងការការពារសិទ្ធិទាំងនេះ។

អ្នកទាំងបីនេះ ដែលត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ផ្តន្ទាទោសពីបទញុះញង់ឱ្យមានភាពវឹកវរក្នុងសង្គម បានស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលប្រាំបីខែ មុនការផ្តន្ទាទោស។

"សេចក្តីសម្រេចរបស់តុលាការកម្ពុជា ដែលផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្សទាំងបីរូបដាក់ពន្ធនាគារ គឺជាការគួរឱ្យខ្មាស់អៀន ហើយដោយគ្រាន់តែពង្រឹងគោលនយោបាយយូរអង្វែងរបស់រដ្ឋាភិបាលដើម្បីកាត់បន្ថយលំហពលរដ្ឋ និងសំឡេងប្រឆាំង។" នេះបើតាមប្រសាសន៍របស់អ្នកស្រី ម៉ារី ឡលរ័ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស។

"សាលក្រមបានបង្ហាញផងដែរពីរបៀបដែលតុលាកាមិនអាច និងមិនមានឆន្ទៈក្នុងការលើកកំពស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលរដ្ឋាភិបាលបានទទួលយកដោយស្ម័គ្រចិត្ត។ ខ្ញុំមានកង្វល់អំពីលំនាំនៃការចោទប្រកាន់ដែលកាន់តែកើនឡើងទៅលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ចាប់តាំងពីខែកក្កដា ឆ្នាំ២០២០ មក។ "ការជំនុំជម្រះ និងការផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្សនៃ អង្គការមាតាធម្មជាតិ (អិម អិន ស៊ី) បង្ហាញយ៉ាងច្បាស់នូវការមិនអត់ឱននៅតែបន្តមាន និងការខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយលំហសម្រាប់អ្នកការពារសិទ្ធិមនុស្ស" ។

"ការសម្រេចនេះ ធ្វើឲ្យមានកង្វល់យ៉ាងខ្លាំង ខណៈដែលរដ្ឋទាំងឡាយមានកាតព្វកិច្ចផ្តល់នូវបរិស្ថានមានសុវត្ថិភាពនិងអំណោយផល ដែលក្នុងនោះអ្នកការពារសិទ្ធិមនុស្សផ្នែកបរិស្ថានអាចប្រតិបត្តិ

ការងារដោយគ្មានការគំរាមកំហែង ការយាយីរំខាន ការបំភិតបំភ័យ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងអំពើហឹង្សា"។ នេះបើតាមការគូសបញ្ជាក់របស់បណ្ឌិត ដេវីដ ប៊យ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្ស និងបរិស្ថាន ។

មនុស្សបីនាក់ត្រូវបានចាប់ខ្លួនក្នុងខែកញ្ញា ឆ្នាំ២០២០ ដោយគ្មានដីកា ហើយត្រូវបានចោទប្រកាន់តាមមាត្រា៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ។ បទចោទនេះ នឹងត្រូវទទួលទោសជាប់ពន្ធនាគារចន្លោះពីប្រាំមួយខែ ទៅពីរឆ្នាំ និងពិន័យជាប្រាក់ពីមួយលាន រៀល ទៅបួនលានរៀល (ប្រមាណ ២៥០ ទៅ ១.000 ដុល្លារអាមេរិក) ។

អ្នកស្រី ឡល័រ បានសម្តែងកង្វល់យ៉ាងខ្លាំងអំពីកង្វះភ័ស្តុតាងជាក់ស្តែងដែលគាំទ្រដល់ការចោទប្រកាន់នេះ។ អ្នកការពារសិទ្ធិមនុស្ស ត្រូវបានផ្តន្ទាទោសផ្អែកលើការបង្ហោះសារ ឬរូបភាពមួយចំនួនអំពីការងារបរិស្ថានតាមបណ្តាញសង្គមហ្វេសប៊ុក និងឃ្លីបវីដេអូដែលបានបង្ហាញពីសកម្មភាពរបស់ពួកគេក្នុងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្ស និងបរិស្ថាន តាមលក្ខណៈជាក់ស្តែង និងដោយសន្តិវិធី។ មិនមានភ័ស្តុតាងរឹងមាំណាមួយ ត្រូវបានបង្ហាញអំពីសកម្មភាពរបស់ពួកគេថាពិតជាមានជាក់ស្តែង ឬអាចនាំឱ្យមាន " ភាពវឹកវរក្នុងសង្គម" ឡើយ។

"ទោះបីជាអ្នកការពារសិទ្ធិមនុស្សទាំងបីរូបនេះ នៅតែអាចមានសិទ្ធិប្តឹងឧទ្ធរណ៍បានក៏ដោយ ក៏ខ្ញុំសូមឱ្យរដ្ឋាភិបាលកម្ពុជា ដោះលែងពួកគេជាបន្ទាន់ និងដោយគ្មានល័ក្ខខ័ណ្ឌ។ គ្មាននរណាម្នាក់ត្រូវបានគេដាក់ទោសព្រហ្មទណ្ឌ ដោយសារតែសកម្មភាពការងារសិទ្ធិមនុស្សស្របច្បាប់នោះទេ"។ អ្នករាយការណ៍ពិសេសបានមានប្រសាសន៍ដូច្នេះ។ "ដូចដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ចុងក្រោយរបស់ខ្ញុំក្នុងខែវិច្ឆិកា ខ្ញុំអំពាវនាវដល់ប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា គាំទ្រដល់អ្នកការពារសិទ្ធិមនុស្សទាំងអស់ ដែលបាននិងកំពុងប្រឈមនឹងហានិភ័យ"។

ការអំពាវនាវរបស់អ្នកជំនាញត្រូវបានអនុម័តយល់ព្រមដោយ លោក **ដេវីដ ប៊យ** អ្នករាយការណ៍ពិសេស ស្តីពីបញ្ហាកាតព្វកិច្ចសិទ្ធិមនុស្សទាក់ទងនឹងសិទ្ធិទទួលបានបរិស្ថានស្អាត អនាម័យ សុខភាព និងប្រកបដោយចីរភាព។ លោក ***ក្លេម៉ែនត៍ នីយ៉ាលេតសូស្សី វ៉ូលេ*** (Clement Nyaletsossi Voule) អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិក្នុងការជួបជុំដោយសន្តិវិធី និងសិទ្ធិសមាគម។

ចប់

***អ្នកស្រី ម៉ារី ឡល័រ*** *(អៀរឡង់) ជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស។ បច្ចុប្បន្ននេះ អ្នកស្រីជាសាស្ត្រាចារ្យផ្នែកធុរកិច្ច និងសិទ្ធិមនុស្សនៅមហាវិទ្យាល័យទ្រីនីធី ទីក្រុង ដាប់លីន។ អ្នកស្រីជាស្ថាបនិកនៃក្រុមអ្នកការពារខ្សែរជួរមុខ - មូលនិធិអន្តរជាតិសម្រាប់ការពារ អ្នកការពារសិទ្ធិមនុស្ស។ ក្នុងនាមជានាយកប្រតិបត្តិចាប់ពីឆ្នាំ២០០១-២០១៦ លោកស្រីបានតំណាង អ្នកការពារជួរមុខ និងមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍មូលនិធិនេះ។ អ្នកស្រី ម៉ារី ឡល័រ ជាប្រធាន ផ្នែកអៀរឡង់ នៃអង្គការលើកលែងទោសអន្តរជាតិ*

*ចាប់ពីឆ្នាំ១៩៨៨ ដល់ឆ្នាំ២០០០ បានក្លាយជាសមាជិក ក្រុមប្រឹក្សាភិបាលនៅឆ្នាំ១៩៧៥ និងត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានចាប់ពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៧ ។*

*អ្នករាយការណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលដោះស្រាយស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ក្រុមអ្នកជំនាញនៃនីតិវិធីពិសេស ធ្វើការផ្អែក លើគោលការណ៍ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយមិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ខ្លួនឡើយ។ ពួកគេធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ។*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទង៖ លោក អ័រសូឡាយ ថូត តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៩១៣) ឬអ៊ីម៉ែល /ototh@ohchr.org) ឬសរសេរទៅកាន់ defenders@ohchr.org.*

*សម្រាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖ រេណាតូ ឌឺ ស៊ូហ្សា (Renato de Souza) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៨៥៥ ឬអ៊ីម៉ែល៖ rrosariodesouza@ohchr.org) លោកជេរ៉ឺមី ឡូរិន (Jeremy Laurence) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៧៥៧៨ / ឬអ៊ីម៉ែល៖ jlaurence@ohchr.org) និង ឃីតធី ម៉ាកឃីនសី (Kitty McKinsey) តាមរយៈអ៊ីម៉ែល៖ kmckinsey@ohchr.org) ។*

*តាមដានព័ត៌មានទាក់ទងនឹងក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់ អ.ស.ប តាមបណ្តាញទ្វីធទ័រ Twitter@UN_SPExperts*

*តើអ្នកខ្វល់អំពីពិភពលោកដែលយើងរស់ ឬទេ?*

***ដូច្នេះ ក្រោកឈរ ដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។***

*ហើយចូលទៅកាន់គេហទំព័រ http://www.standup4humanrights.org*